ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា



ប្រធានគណៈមេធាវី

មេធាវី សួន វិសាល

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី កុយ នាម
២-មេធាវី ទេព បូផល
៣-មេធាវី ពេជ្រ សុរិយា
៤-មេធាវី ជុំ សុវណ្ណាលី
៥-មេធាវី ប៉ា ចូនគា
៦-មេធាវី ចេង ប៉េងហាប់
៧-មេធាវី យុង ផានិត
៨-មេធាវី ចៅ ប៊ុនហួន
៩-មេធាវី រស់ មុនិន្ទ:
១០-មេធាវី តែ ចំណាន
១១-មេធាវី ខុច ចន្ធា
១២-មេធាវី ហួង គីមសួន
១៣-មេធាវី ឱុយ សុខសុលីដា
១៤-មេធាវី សួន ប៊ុនធឿន
១៥-មេធាវី កេង សុម៉ារតន៍
១៦-មេធាវី ពិន វណ្ណៈ
១៧-មេធាវី ច័ន្ទ វិចិត្រ
១៨-មេធាវី ព្រហ្ម វិចិត្រសុភា
១៩-មេធាវី ណុប គុណថុល
២០-មេធាវី យឹម ថាវី
២១-មេធាវី ឌឹម ចៅសេង
២២-មេធាវី លី សុខឡាយ
២៣-មេធាវី ស៊ុយ ឈុនហាក់
២៤-មេធាវី គង់ សំអុន
២៥-មេធាវី ហាក់ សៀកលី
២៦-មេធាវី គង់ សុភ័ក្រ្ត
២៧-មេធាវី គាន តារា
២៨-មេធាវី ម៉ាង ហុង
២៩-មេធាវី ឈរ លីថៃ
៣០-មេធាវី ម៉ុម ពិសី
៣១-មេធាវី ទ្រី សំរស់
៣២-មេធាវី នួន ផានិត
៣៣-មេធាវី យុត កែវសុត្ថា


លេខ ៣៦៩ /សសគម/១៩

ថ្ងៃ សុក្រ ១១កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៩

# សេចក្តីសម្រេច

## ស្តីពី

## ការកំណត់ប្រភេទអាវវិជ្ជាជីវៈមេធាវី និងអាវសម្រាប់មេធាវីពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យរបស់គណៈមេធាវី

## គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ ២០១៦
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **សួន វិសាល** ជាប្រធានគណៈមេធាវីអាណត្តិទី ១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៩
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០១៩។

## ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

សេចក្ដីសម្រេចនេះមានគោលបំណងលើកស្ទួយតម្លៃ សេចក្ដីថ្លៃថ្នូរ និងការគោរពវិជ្ជាជីវៈមេធាវី ព្រមទាំងលើកតម្កើងកិត្តិយសរបស់គណៈមេធាវី និងមេធាវីគ្រប់រូប តាមរយៈការជំរុញ និងលើកទឹកចិត្តឱ្យមានការគោរព និងឱ្យតម្លៃគ្នាទៅវិញទៅមករវាងមេធាវី និងមេធាវី ក្នុងការប្រកបវិជ្ជាជីវៈមេធាវី និងក្នុងពិធីជាផ្លូវការនានារបស់គណៈមេធាវី ។

**ប្រការ ២.- គោលដៅ**

សេចក្ដីសម្រេចនេះមានគោលដៅកំណត់អំពីប្រភេទអាវសម្រាប់ពាក់ក្នុងពេលប្រកបវិជ្ជាជីវៈមេធាវី និងប្រភេទអាវសម្រាប់ពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី ។

**ប្រការ ៣.- វិសាលភាព**

សេចក្ដីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះមេធាវីកម្មសិក្សា និងមេធាវី ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២

## ប្រភេទអាវមេធាវី

**ប្រការ ៤.- ប្រភេទអាវសម្រាប់មេធាវី**

អាវសម្រាប់មេធាវីមានចំនួន ០៦(ប្រាំមួយ)ប្រភេទដូចខាងក្រោម៖

១-អាវសម្រាប់ប្រធានគណៈមេធាវី ។

២-អាវសម្រាប់អតីតប្រធានគណៈមេធាវី ។

៣-អាវសម្រាប់សមាជិកក្រុមប្រឹក្សាគណៈមេធាវី ។

៤-អាវសម្រាប់អតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវី ។

៥-អាវសម្រាប់មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាប់ពី ១៥ ឆ្នាំឡើងទៅ។

៦-អាវវិជ្ជាជីវៈមេធាវី ។

**ប្រការ ៥.- អាវសម្រាប់ប្រធានគណៈមេធាវី**

អាវសម្រាប់ប្រធានគណៈមេធាវីត្រូវមានលក្ខណៈដូចខាងក្រោម៖

ក-ជាអាវរ៉ូបមានផ្ទៃអាវពណ៌ខ្មៅ ដៃវែង ។

ខ-នៅលើស្មាខាងឆ្វេងមានក្រវ៉ាត់ពណ៌ខ្មៅទម្លាក់ចុះទៅមុខ និងទៅក្រោយដែលមានលក្ខណៈដូចខាងក្រោម៖

- ក្រវ៉ាត់ស្មានេះត្រូវមានបូមូលពណ៌ខ្មៅនៅចំកណ្តាលស្មាដែលមានអង្កត់ផ្ចិតប្រវែង ៥,៥ សម
- ចំពោះក្រវ៉ាត់ទម្លាក់មកមុខខ្លីជាងចុងនៃដៃអាវ ១២ សម ទទឹងផ្នែកខាងលើមានប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ២០ សម មានផ្នត់ធំចំកណ្តាលមួយអមដោយផ្នត់តូចៗចំនួនបីអមសងខាង នៅលើជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណ៌មាសប្រវែង ៤ សម។ ហើយនៅចំកណ្តាលក្រវ៉ាត់ស្មាផ្នែកខាងមុខមានប៉ាក់រូបសញ្ញារបស់គណៈមេធាវីដែលមានពណ៌មាស និងមានអង្កត់ផ្ចិតប្រវែង ៨សម។ រូបសញ្ញាគណៈមេធាវីនេះស្ថិតនៅប្រវែង១៥សម គិតពីចំណុចកណ្តាលនៃបូលើស្មាចុះមកក្រោម
- ចំពោះក្រវ៉ាត់ទម្លាក់មកក្រោយមានប្រវែង ៦៥ សម ទទឹងផ្នែកខាងលើប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានរំយោលពណ៌មាសប្រវែង ៤ សម។

គ-នៅចំពីមុខមានក្រវ៉ាត់កពណ៌សទម្លាក់ពីកអាវមកដើមទ្រូងខ្លីជាងក្រវ៉ាត់ស្មាដែលទម្លាក់មកមុខ ១៥ សម ទទឹងផ្នែកខាងលើប្រវែង ៤ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានផ្នត់ធំចំកណ្តាលមួយអមដោយផ្នត់តូចៗចំនួន ៣ សងខាង។

ឃ-នៅផ្នែកខាងមុខអាវមានក្បាច់ភ្ជីទេសពណ៌មាសសំយុងតាមជាយអាវទាំងសងខាង ដែលមានទទឹងប្រវែង ១០ សម។

ង-នៅជុំវិញកអាវមានក្បាច់ភ្ជីទេសពណ៌មាសដែលមានទទឹងប្រវែង ៤ សម។

ច-នៅចុងដៃអាវទាំងសងខាងមានក្បាច់ភ្ជីទេសពណ៌មាស និងមានឆ្នូតសក្តិពណ៌មាសចំនួនបី ដាក់នៅពីលើភ្ជីទេសនោះ ដែលមានទទឹងប្រវែង ៧,៥ សម។

រូបភាពនៃអាវសម្រាប់ប្រធានគណៈមេធាវីមានភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃសេចក្តីសម្រេចនេះ។

## ប្រការ ៦.. អាវសម្រាប់អតីតប្រធានមេធាវី

អាវសម្រាប់អតីតប្រធានគណៈមេធាវីត្រូវមានលក្ខណៈដូចខាងក្រោម៖

ក-ជាអាវរ៉ូបមានផ្ទៃអាវពណ៌ខ្មៅ ដៃវែង។

ខ-នៅលើស្មាខាងឆ្វេងមានក្រវ៉ាត់ពណ៌ខ្មៅទម្លាក់ចុះទៅមុខ និងទៅក្រោយដែលមានលក្ខណៈដូចខាងក្រោម៖

- ក្រវ៉ាត់ស្មានេះត្រូវមានបូមូលពណ៌ខ្មៅនៅចំកណ្តាលស្មាដែលមានអង្កត់ផ្ចិតប្រវែង ៥,៥ សម
- ចំពោះក្រវ៉ាត់ទម្លាក់មកមុខខ្លីជាងចុងនៃដៃអាវ ១២ សម ទទឹងផ្នែកខាងលើមានប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ២០ សម មានផ្នត់ធំចំកណ្តាលមួយអមដោយផ្នត់តូចៗចំនួនបីអមសងខាង នៅលើជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណ៌សប្រវែង ៤ សម

- ចំពោះក្រវ៉ាត់ទម្លាក់មកក្រោយមានប្រវែង ៦៥ សម ទទឹងផ្នែកខាងលើប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានរំយោលពណ៌សប្រវែង ៤ សម។

គ-នៅចំពីមុខមានក្រវ៉ាត់កពណ៌សទម្លាក់ពីកអាវមកដើមទ្រូងខ្ពស់ជាងក្រវ៉ាត់ស្មាដែលទម្លាក់មកមុខ ១៥ សម ទទឹងផ្នែកខាងលើប្រវែង ៤ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានផ្កាត់ធំចំកណ្ដាលមួយអមដោយផ្កាត់តូចៗចំនួន ៣ សងខាង។

ឃ-នៅផ្នែកខាងមុខអាវមានក្បាច់ភ្ញីទេសពណ៌មាសសំយុងតាមជាយអាវទាំងសងខាង ដែលមានទទឹងប្រវែង ១០ សម។

ង-នៅជុំវិញកអាវមានក្បាច់ភ្ញីទេសពណ៌មាសដែលមានទទឹងប្រវែង ៤ សម។

ច-នៅចុងដៃអាវទាំងសងខាងមានក្បាច់ភ្ញីទេសពណ៌មាស និងមានឆ្នូតសក្តិពណ៌មាសចំនួនបី ដាក់នៅពីលើភ្ញីទេសនោះ ដែលមានទទឹងប្រវែង ៧,៥ សម។

រូបភាពនៃអាវសម្រាប់អតីតប្រធានគណៈមេធាវីមានភ្ជាប់ជាឧបសម្ព័ន្ធទី២ នៃសេចក្តីសម្រេចនេះ។

## ប្រការ ៧.. អាវសម្រាប់សមាជិកក្រុមប្រឹក្សាមេធាវី

អាវសម្រាប់សមាជិកក្រុមប្រឹក្សាគណៈមេធាវីត្រូវមានលក្ខណៈដូចខាងក្រោម៖

ក-ជាអាវរ៉ូបមានផ្ទៃអាវពណ៌ខ្មៅ ដៃវែង។

ខ-នៅលើស្មាខាងឆ្វេងមានក្រវ៉ាត់ស្មាពណ៌ខ្មៅទម្លាក់ចុះទៅមុខ និងទៅក្រោយ ដែលមានលក្ខណៈដូចខាងក្រោម៖

- ក្រវ៉ាត់ស្មានេះត្រូវមានបូមូលពណ៌ខ្មៅនៅចំកណ្ដាលស្មាដែលមានអង្កត់ផ្ចិតប្រវែង ៥,៥ សម
- ចំពោះក្រវ៉ាត់ទម្លាក់មកមុខខ្ពស់ជាងចុងនៃដៃអាវ ១២ សម ទទឹងផ្នែកខាងលើមានប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ២០ សម មានផ្កាត់ធំចំកណ្ដាលមួយអមដោយផ្កាត់តូចៗចំនួនបីអមសងខាង នៅលើជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណ៌សប្រវែង ៤ សម។ ហើយនៅចំកណ្ដាលក្រវ៉ាត់ស្មាផ្នែកខាងមុខមានប៉ាក់រូបសញ្ញារបស់គណៈមេធាវីដែលមានពណ៌មាស និងមានអង្កត់ផ្ចិតប្រវែង ៨សម។ រូបសញ្ញាគណៈមេធាវីនេះស្ថិតនៅប្រវែង១៥សម គិតពីចំណុចកណ្ដាលនៃបូលើស្មាចុះមកក្រោម
- ចំពោះក្រវ៉ាត់ទម្លាក់មកក្រោយមានប្រវែង ៦៥ សម ទទឹងផ្នែកខាងលើប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានរំយោលពណ៌សប្រវែង ៤ សម។

គ-នៅចំពីមុខមានក្រវ៉ាត់កពណ៌សទម្លាក់ពីកអាវមកដើមទ្រូងខ្ពស់ជាងក្រវ៉ាត់ស្មាដែលទម្លាក់មកមុខ ១៥ សម ទទឹងផ្នែកខាងលើប្រវែង ៤ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានផ្កាត់ធំចំកណ្ដាលមួយអមដោយផ្កាត់តូចៗចំនួន ៣ សងខាង។

ឃ-នៅផ្នែកខាងមុខអាវមានក្បាច់ភ្ញីទេសពណ៌មាសសំយុងតាមជាយអាវទាំងសងខាង ដែលមានទទឹងប្រវែង ១០ សម។

ង-នៅចុងដៃអាវទាំងសងខាងមានក្បាច់ភ្ញីទេសពណ៌មាស ដែលមានទទឹងប្រវែង ៧,៥ សម ។

រូបភាពនៃអាវសម្រាប់សមាជិកក្រុមប្រឹក្សាគណៈមេធាវីមានភ្ជាប់ជាឧបសម្ព័ន្ធទី៣ នៃសេចក្តីសម្រេចនេះ ។

**ប្រការ ៨.. អាវសម្រាប់អតីតសមាជិកក្រុមប្រឹក្សាមេធាវី**

អាវសម្រាប់អតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវីត្រូវមានលក្ខណៈដូចខាងក្រោម៖

ក-ជាអាវរ៉ូបមានផ្ទៃអាវពណ៌ខ្មៅ ដៃវែង ។

ខ-នៅលើស្មាខាងឆ្វេងមានក្រវ៉ាត់ស្មានៅលើស្មាខាងឆ្វេងពណ៌ខ្មៅទម្លាក់ចុះទៅមុខ និងទៅក្រោយ ដែលមានលក្ខណៈដូចខាងក្រោម៖

- ក្រវ៉ាត់ស្មានេះត្រូវមានបូមូលពណ៌ខ្មៅនៅចំកណ្តាលស្មាដែលមានអង្កត់ផ្ចិតប្រវែង ៥,៥ សម
- ចំពោះក្រវ៉ាត់ទម្លាក់មកមុខខ្លីជាងចុងនៃដៃអាវ ១២ សម ទទឹងផ្នែកខាងលើមានប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ២០ សម មានផ្នត់ធំចំកណ្តាលមួយអមដោយផ្នត់តូចៗចំនួនបីអមសងខាង នៅលើជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណ៌សប្រវែង ៤ សម ។ ហើយនៅចំកណ្តាលក្រវ៉ាត់ស្មាផ្នែកខាងមុខមានប៉ាក់រូបសញ្ញារបស់គណៈមេធាវីដែលមានពណ៌មាស និងមានអង្កត់ផ្ចិតប្រវែង ៨ សម
- ចំពោះក្រវ៉ាត់ទម្លាក់មកក្រោយមានប្រវែង ៦៥ សម ទទឹងផ្នែកខាងលើប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានរំយោលពណ៌សប្រវែង ៤ សម ។

គ-នៅចំពីមុខមានក្រវ៉ាត់កពណ៌សទម្លាក់ពីកអាវមកដើមទ្រូងខ្លីជាងក្រវ៉ាត់ស្មាដែលទម្លាក់មកមុខ ១៥ សម ទទឹងផ្នែកខាងលើប្រវែង ៤ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានផ្នត់ធំចំកណ្តាលមួយអមដោយផ្នត់តូចៗចំនួន ៣ សងខាង ។

ឃ-នៅផ្នែកខាងមុខអាវមានក្បាច់ភ្ញីទេសពណ៌មាសសំយុងតាមជាយអាវទាំងសងខាង ដែលមានទទឹងប្រវែង ១០ សម ។

ង-នៅចុងដៃអាវទាំងសងខាងមានក្បាច់ភ្ញីទេសពណ៌មាស ដែលមានទទឹងប្រវែង ៧,៥ សម ។

រូបភាពនៃអាវសម្រាប់អតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវីមានភ្ជាប់ជាឧបសម្ព័ន្ធទី៤ នៃសេចក្តីសម្រេចនេះ ។

**ប្រការ ៩.. អាវសម្រាប់មេធាវីដែលបានចុះបញ្ជីគណៈមេធាវីចាប់ពី ១៥(ដប់ប្រាំ)ឆ្នាំឡើង**

អាវសម្រាប់មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាប់ពី ១៥ (ដប់ប្រាំ)ឆ្នាំឡើងទៅត្រូវមានលក្ខណៈដូចខាងក្រោម៖

ក-ជាអាវរ៉ូបមានផ្ទៃអាវពណ៌ខ្មៅ ដៃវែង ។

ខ-នៅលើស្មាខាងឆ្វេងមានក្រវ៉ាត់ពណ៌ខ្មៅទម្លាក់ចុះទៅមុខ និងទៅក្រោយ ដែលមានលក្ខណៈដូចខាងក្រោម៖

- ក្រវ៉ាត់ស្មានេះត្រូវមានបូមូលពណ៌ខ្មៅនៅចំកណ្តាលស្មាដែលមានអង្កត់ផ្ចិតប្រវែង ៥,៥ សម

- ចំពោះក្រវ៉ាត់ទម្លាក់មកមុខខ្លីជាងចុងនៃដៃអាវ ១២ សម ទទឹងផ្នែកខាងលើមានប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ២០ សម មានផ្ទត់ធំចំកណ្ដាលមួយអមដោយផ្ទត់តូចៗចំនួនបីអមសងខាង នៅលើជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណ៌មាសប្រវែង ៤ សម
- ចំពោះក្រវ៉ាត់ទម្លាក់មកក្រោយមានប្រវែង ៦៥ សម ទទឹងផ្នែកខាងលើប្រវែង ៥ សម ទទឹង ផ្នែកខាងក្រោមប្រវែង ១៣ សម និងមានរំយោលពណ៌មាសប្រវែង ៤ សម។

គ-នៅចំពីមុខមានក្រវ៉ាត់កពណ៌សទម្លាក់ពីកអាវមកដើមទ្រូងខ្លីជាងក្រវ៉ាត់ស្មាដែលទម្លាក់មកមុខ ១៥ សម ទទឹងផ្នែកខាងលើប្រវែង ៤ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានផ្ទត់ធំចំកណ្ដាលមួយអមដោយផ្ទត់តូចៗចំនួន ៣ សងខាង។

ឃ-នៅផ្នែកខាងមុខអាវមានឆ្នូតសក្តិពណ៌មាសចំនួនបីសំយុងតាមជាយអាវទាំងសងខាង ដែលមានទទឹងប្រវែង ៥ សម ហើយក្នុងឆ្នូតសក្តិនីមួយៗមានទទឹងប្រវែង ១,២ សម។

ង-នៅចុងដៃអាវទាំងសងខាងមានឆ្នូតសក្តិពណ៌មាសចំនួនបី ដែលមានទទឹងប្រវែង ៥ សម ហើយក្នុងឆ្នូតសក្តិនីមួយៗមានទទឹងប្រវែង ១,២ សម។

រូបភាពនៃអាវសម្រាប់មេធាវី ដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាប់ពី១៥ឆ្នាំឡើងទៅមានភ្ជាប់ជាឧបសម្ព័ន្ធទី៥ នៃសេចក្តីសម្រេចនេះ។

**ប្រការ ១០.. អាវសម្រាប់មេធាវីដែលបានចុះបញ្ជីគណៈមេធាវីតិចជាង ១៥ (ដប់ប្រាំ)ឆ្នាំ និងមេធាវីកម្មសិក្សា**

អាវសម្រាប់មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីតិចជាង ១៥ (ដប់ប្រាំ)ឆ្នាំ និងមេធាវីកម្មសិក្សាត្រូវមានលក្ខណៈដូចខាងក្រោម៖

ក-ជាអាវរ៉ូបមានផ្ទៃអាវពណ៌ខ្មៅ ដៃវែង។

ខ-នៅលើស្មាខាងឆ្វេងមានក្រវ៉ាត់ពណ៌ខ្មៅទម្លាក់ចុះទៅមុខ និងទៅក្រោយ ដែលមានលក្ខណៈដូចខាងក្រោម៖

- ក្រវ៉ាត់ស្មានេះត្រូវមានបូមូលពណ៌ខ្មៅនៅចំកណ្ដាលស្មាដែលមានអង្កត់ផ្ចិតប្រវែង ៥,៥ សម
- ចំពោះក្រវ៉ាត់ទម្លាក់មកមុខខ្លីជាងចុងនៃដៃអាវ ១២ សម ទទឹងផ្នែកខាងលើមានប្រវែង ៥សម ទទឹងផ្នែកខាងក្រោមប្រវែង ២០ សម មានផ្ទត់ធំចំកណ្ដាលមួយអមដោយផ្ទត់តូចៗចំនួនបីអមសងខាងនៅលើ ជាយខាងក្រោមនៃក្រវ៉ាត់នោះមានរំយោលពណ៌សប្រវែង ៤ សម
- ចំពោះក្រវ៉ាត់ទម្លាក់មកក្រោយមានប្រវែង ៦៥ សម (រួមទាំងរំយោល) ទទឹងផ្នែកខាងលើប្រវែង ៥ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានរំយោលពណ៌សប្រវែង ៤ សម។

គ-នៅចំពីមុខមានក្រវ៉ាត់កពណ៌សទម្លាក់ពីកអាវមកដើមទ្រូងខ្លីជាងក្រវ៉ាត់ស្មាដែលទម្លាក់មកមុខ ១៥ សម ទទឹងផ្នែកខាងលើប្រវែង ៤ សម ទទឹងផ្នែកខាងក្រោមប្រវែង ១៣ សម និងមានផ្ទត់ធំចំកណ្ដាលមួយអមដោយផ្ទត់តូចៗចំនួន ៣ សងខាង។

ឃ-នៅផ្នែកខាងមុខអាវមានក្រណាត់រលោងពណ៌ខ្មៅសំយុងតាមជាយអាវទាំងសងខាង ដែលមានទទឹងប្រវែង ១៥ សម

ង-នៅចុងដៃអាវទាំងសងខាងមានក្រណាត់រលោងពណ៌ខ្មៅ ដែលមានទទឹងប្រវែង ១៥ សម។

រូបភាពនៃអាវវិជ្ជាជីវៈមេធាវីនេះមានភ្ជាប់ជាឧបសម្ព័ន្ធទី៦ នៃសេចក្តីសម្រេចនេះ។

## ជំពូកទី ៣
## ការប្រើប្រាស់អាវមេធាវី

**ប្រការ ១១.- ការប្រើប្រាស់អាវក្នុងពេលប្រកបវិជ្ជាជីវៈមេធាវី**

ក្នុងពេលប្រកបវិជ្ជាជីវៈមេធាវីនៅចំពោះមុខសវនាការ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងនៅចំពោះមុខយុត្តាធិការគ្រប់ប្រភេទ មេធាវីគ្រប់រូប រួមទាំងប្រធានគណៈមេធាវី និងក្រុមប្រឹក្សាគណៈមេធាវីត្រូវពាក់អាវវិជ្ជាជីវៈមេធាវីដូចបានកំណត់ក្នុងប្រការ ១០ ខាងលើ លើកលែងតែមានប្រពៃណីផ្ទុយពីនេះ។

**ប្រការ ១២.- ការប្រើប្រាស់អាវក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី**

ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី ប្រធានគណៈមេធាវីក្នុងតំណែងត្រូវពាក់អាវ ដូចបានកំណត់ក្នុងប្រការ ៥ នៃសេចក្តីសម្រេចនេះ។

ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី អតីតប្រធានគណៈមេធាវីត្រូវពាក់អាវ ដូចបានកំណត់ក្នុងប្រការ ៦ នៃសេចក្តីសម្រេចនេះ។

ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី សមាជិកក្រុមប្រឹក្សាគណៈមេធាវីក្នុងតំណែងត្រូវពាក់អាវដូចបានកំណត់ក្នុងប្រការ ៧ នៃសេចក្តីសម្រេចនេះ។

ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី អតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវីត្រូវពាក់អាវដូចបានកំណត់ក្នុងប្រការ ៨ នៃសេចក្តីសម្រេចនេះ។

ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាប់ពី ១៥ (ដប់ប្រាំ)ឆ្នាំឡើងទៅត្រូវពាក់អាវ ដូចបានកំណត់ក្នុងប្រការ ៩ នៃសេចក្តីសម្រេចនេះ។

ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីតិចជាង ១៥ (ដប់ប្រាំ)ឆ្នាំ និងមេធាវីកម្មសិក្សាត្រូវពាក់អាវ ដូចបានកំណត់ក្នុងប្រការ ១០ នៃសេចក្តីសម្រេចនេះ។

## ជំពូកទី ៤
## ទណ្ឌកម្មវិន័យ

**ប្រការ ១៣.- ការដាក់ទណ្ឌកម្ម និង/ឬការផ្តន្ទាទោសចំពោះមេធាវី និងជនទូទៅ**

បុគ្គលដែលខ្លួនពុំមានសិទ្ធិបានពាក់ជាសាធារណៈនូវអាវប្រភេទណាមួយដូចបានកំណត់ក្នុងប្រការ ៥ ប្រការ ៦ ប្រការ ៧ ប្រការ ៨ ប្រការ ៩ និងប្រការ ១០ នៃសេចក្តីសម្រេចនេះនឹងត្រូវទទួលរងនូវទណ្ឌកម្មវិន័យតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី ឬត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ ១៤.- ការដាក់ទណ្ឌកម្មចំពោះមេធាវី**

មេធាវីជាសមាជិកគណៈមេធាវី រួមទាំងមេធាវីកម្មសិក្សាណាម្នាក់ ដែលបានប្រើប្រាស់អាវមេធាវីផ្ទុយនឹងខ្លឹមសារដូចមានចែងក្នុងប្រការខាងលើនៃសេចក្តីសម្រេចនេះ ត្រូវទទួលរងនូវទណ្ឌកម្មវិន័យតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ១៥.- ការទុកជានិរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១៦.- ការអនុវត្ត**

អគ្គលេខាធិការ និងសមាជិក សមាជិកាគណៈមេធាវី និងមេធាវីកម្មសិក្សាទាំងអស់ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ប្រធាន**

មេធាវី សួន_វិសាល

***ចម្លងជូន***

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ក្រុមប្រឹក្សាគណៈមេធាវី

"ដើម្បីជ្រាប"

-ដូចប្រការ ១៦

-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃសេចក្តីសម្រេចលេខ៣៦៩/សសគម/១៩ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩

# អាវសម្រាប់ប្រធានគណៈមេធាវីពាក់ក្នុងពិធីផ្លូវការនិងពិធីបុណ្យនានារបស់គណៈមេធាវី









ឧបសម្ព័ន្ធទី២ នៃសេចក្តីសម្រេចលេខ៣៦៩/សសគម/១៩ ចុះថ្ងៃទី១២ខែកក្កដា ឆ្នាំ២០១៩

**អាវសម្រាប់អតីតប្រធានគណៈមេធាវីពាក់ក្នុងពិធីផ្លូវការនិងពិធីបុណ្យនានារបស់គណៈមេធាវី**



ឧបសម្ព័ន្ធទី៣ នៃសេចក្តីសម្រេចលេខ៣៣៥/សសគម/១៩ ចុះថ្ងៃទី១២ខែកក្កដា ឆ្នាំ២០១៩

**អាវសម្រាប់សមាជិកក្រុមប្រឹក្សាគណៈមេធាវីពាក់ក្នុងពិធីផ្លូវការនិងពិធីបុណ្យនានារបស់គណៈមេធាវី**



ឧបសម្ព័ន្ធទី៤ នៃសេចក្ដីសម្រេចលេខ៣៦៩/សសគម/១៩ ចុះថ្ងៃទី១២ខែកក្កដា ឆ្នាំ២០១៩

**អាវសម្រាប់អតីតសមាជិកក្រុមប្រឹក្សាគណៈមេធាវីពាក់ក្នុងពិធីផ្លូវការនិងពិធីបុណ្យនានារបស់គណៈមេធាវី**



ឧបសម្ព័ន្ធទី៥នៃសេចក្តីសម្រេចលេខ៣៦៩/សសគម/១៩ចុះថ្ងៃទី១២ខែកក្កដា ឆ្នាំ២០១៩

**អាវសម្រាប់មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីចាប់ពី១៥ឆ្នាំឡើងទៅ ពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី**









ឧបសម្ព័ន្ធទី៦ នៃសេចក្តីសម្រេចលេខ៣៦៩/សសគម/១៩ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩

**អាវវិជ្ជាជីវៈមេធាវី និងសម្រាប់មេធាវីដែលបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវី តិចជាង១៥ឆ្នាំ និងមេធាវី កម្មសិក្សាពាក់ក្នុងពិធីផ្លូវការ និងពិធីបុណ្យនានារបស់គណៈមេធាវី**

